ក្រុមប្រឹក្សារដ្ឋមន្ត្រី
លេខ ០៣ សរណន

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

## សារាចរណែនាំ

## អំពីការអនុវត្តន៍ ច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហារ របស់ពលរដ្ឋ

ច្បាប់ស្តីពីការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ធ្វើឡើងដោយអនុលោមតាមមាត្រា២,៣០,៣២ និង ៣៧ នៃរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងគោលដៅបង្កលក្ខណៈងាយស្រួល ដើម្បីអោយពលរដ្ឋបានចូលរួមក្នុងកិច្ចការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម ព្រមទាំង បានចូលរួមក្នុងកិច្ចការត្រួតពិនិត្យរាល់សកម្មភាពរបស់អង្គការរដ្ឋ អង្គការសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច អង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន និងបុគ្គលនៃអង្គការ ទាំងនោះ ។

មាត្រា២ នៃច្បាប់នេះកំណត់ពីសិទ្ធិប្តឹងតវ៉ា ប្តឹងបរិហាររបស់ពលរដ្ឋ ចំពោះអង្គការរដ្ឋ អង្គការសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច និងអង្គភាពកងកម្លាំងប្រដាប់អាវុធប្រជាជន ឬ បុគ្គលណាម្នាក់ដែលនៅក្រោមឱវាទនៃអង្គការនេះ ដែលបានអនុវត្តខុសពីគោលនយោបាយ និងច្បាប់ហើយធ្វើអោយខូចផលប្រយោជន៍របស់រដ្ឋ របស់សមូហភាព និងប្រយោជន៍ស្របច្បាប់របស់ពលរដ្ឋ ។

បណ្តឹងតវ៉ាគឺជាប្រភេទបណ្តឹងរបស់ពលរដ្ឋ ប្តឹងកើតទុក្ខមិនសុខចិត្តពីស្ថាប័នរដ្ឋ ឬ បុគ្គលិករដ្ឋ ដែលបានប្រព្រឹត្តល្មើសច្បាប់ បណ្តាលអោយប៉ះពាល់ដល់ទ្រព្យសម្បត្តិ សិទ្ធិសេរីភាព កិត្តិយស ឬ រូបរាងកាយរបស់ពលរដ្ឋម្នាក់ ឬច្រើននាក់ ។ ពលរដ្ឋម្នាក់ ឬ ច្រើននាក់ ដែលបានទទួលរងគ្រោះឬ តំណាងស្របច្បាប់របស់ពលរដ្ឋ ដែលរងគ្រោះ មានសិទ្ធិប្តឹង ។ ឯជនដទៃទៀតដែលគ្មានទំនាក់ទំនងក្នុងការរងគ្រោះគ្មានសិទ្ធិប្តឹងទេ ។

បណ្តឹងបរិហារគឺជាប្រភេទបណ្តឹងរបស់ពលរដ្ឋនឹងចោលទោសស្ថាប័នរដ្ឋ ឬ បុគ្គលិករដ្ឋ ដែលបានប្រព្រឹត្តរំលោភច្បាប់បណ្តាលអោយប៉ះពាល់ដល់ផលប្រយោជន៍រួម ឬ ទ្រព្យសម្បត្តិរដ្ឋ មានការលួចកែបំបាត់ កិបកេង ទទួលសំណូក ជំរិតយកប្រាក់ លេងល្បែងស៊ីសង ខុសសីលធម៌ ធ្វើអោយបាត់បង់ ខ្ជះខ្ជាយទ្រព្យសម្បត្តិរដ្ឋ ឆ្លៀតមុខងាររបស់ខ្លួនយកទ្រព្យសម្បត្តិរដ្ឋ ឬ ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ទាញយកកំរៃជាប្រយោជន៍ផ្ទាល់ខ្លួន ។ បណ្តឹងនេះពលរដ្ឋម្នាក់ក្តី ឬ ច្រើននាក់ក្តី អាចនឹងប្តឹងបានទាំងអស់គ្នា ។

ក្នុងការប្តឹងតវ៉ា និង ប្តឹងបរិហារ អ្នកប្តឹងអាចប្តឹងនៅទីកន្លែងណាក៏បាននៅរដ្ឋអំណាចមូលដ្ឋានក្តី ឬនៅមជ្ឈិមក្តី ។

ដើម្បីធានាការអនុវត្តច្បាប់ស្តីពីការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋ

ឲ្យបានហ្មត់ចត់ត្រឹមត្រូវតាមច្បាប់ ក្រុមប្រឹក្សារដ្ឋមន្ត្រី សូមណែនដូចតទៅនេះ ។

*(ការចាត់តាំងទីកន្លែងទទួលប្រជាជន និងទទួលបណ្តឹងតវ៉ា បណ្តឹងបរិហាររបស់ពលរដ្ឋ)*

១-គណៈកម្មធិការប្រជាជនបដិវត្តគ្រប់ថ្នាក់តាំងពី ឃុំ សង្កាត់ ស្រុក ខេត្ត ក្រុង និង អង្គភាពនានា មន្ទីរ ក្រសួងជុំវិញមជ្ឈិម ដែលមានការជួបប្រាស្រ័យទាក់ទងជាមួយប្រជាជន ចាំបាច់ត្រូវបង្កើតកន្លែងទទួលប្រជាជននិងទទួលពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ។

ត្រូវចាត់តាំងកម្មាភិបាល ដែលមានសមត្ថភាពអាចក្តាប់បាននូវគោលនយោបាយរបស់បក្ស និង ច្បាប់របស់រដ្ឋ ហើយមានការយល់ដឹងអំពីភារកិច្ចទទួលខុសត្រូវ និងសមត្ថកិច្ចនានារបស់ស្ថាប័រដ្ឋ មានសីលធម៌ស្អាតស្អំ អត្តចរិតស្លូតបូត សុភាពរាបសារ ដើម្បីធ្វើតំណាងអោយប្រធាននៅប្រចាំការទទួលប្រជាជន និងទទួលពាក្យបណ្តឹង ។

រៀងរាល់ខែ ប្រធានស្ថាប័ន ត្រូវកំណត់ពេលវេលា ដើម្បីជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាជន និង ដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ក្នុងការជួបប្រាស្រ័យជាមួយប្រជាជនជាម្ចាស់បណ្តឹង គណៈកម្មាធិការត្រួតពិនិត្យ ក្រសួង ខេត្ត ក្រុង សង្កាត់ ស្រុក ត្រូវជួយរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការប្រជាជន បដិវត្តខេត្ត ក្រុង ដើម្បីដោះស្រាយរឿងអ្វីដែលកើតឡើង ។

២-កន្លែងទទួលប្រជាជន ត្រូវរៀបចំឡើងនៅទីណាដែលមានសភាពងាយស្រួលជិតផ្លូវទៅមក ហើយត្រូវសរសេរអក្សរធំៗ លើផ្លាកអោយបានច្បាស់ ដើម្បីអោយប្រជាជនដឹងថា ជាកន្លែងទទួលប្រជាជន ឬ ទទួលពាក្យបណ្តឹងរបស់ពលរដ្ឋ ។ ពេលវេលា និង ថ្ងៃ ខែ ដែលប្រធានត្រូវជួបប្រាស្រ័យផ្ទាល់ជាមួយប្រជាជន ក៏ត្រូវកំណត់អោយបានច្បាស់ ហើយត្រូវផ្សាយជាសាធារណៈលើតារាងផ្សាយដំណឹង នៅខាងមុខកន្លែងទទួលប្រជាជន ។

ត្រូវចាត់តាំងអោយកន្លែងអង្គុយយកទឹកក្តៅ មានការសែត ឬ ទស្សនាវដ្តី សម្រាប់អោយប្រជាជនអង្គុយហូប អាន និង មានក្រដាស់ ប៊ិច ឬ ខ្មៅដៃសម្រាប់អោយប្រជាជនសរសេរបំពេញនូវអ្វីៗដែលខ្លួនចង់បន្ថែប ។

៣-កម្មាភិបាលទទួលប្រជាជន និង ទទួលពាក្យបណ្តឹង ត្រូវមានសុជីវធម៌ រួសរាយរាក់ទាក់ជាមួយប្រជាជនមិនត្រូវធ្វើអោយប្រជាជនលំបាក ឬ មានសតិអារម្មណ៍ថ្នាំងថ្នាក់ ត្រូវដោះស្រាយបញ្ហាអោយបានត្រឹមត្រូវតាមគោលនយោបាយរបស់បក្ស និង ច្បាប់រដ្ឋ និងមិនត្រូវអោយទទួលសំណូកសូកប៉ាន់ដាច់ខាត ត្រូវយកចិត្តទុកដាក់ស្តាប់របាយការណ៍ និង កត់ត្រាចូលក្នុងសៀវភៅទទួលបណ្តឹងរបស់ប្រជាជន ដោយចុះលេខ ថ្ងៃ-ខែ-ឆ្នាំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ។ល។ អោយបានគ្រប់ជ្រុងជ្រោយ និង ត្រឹមត្រូវតាម

រឿងពិត ។ លុះកត់ត្រាចប់ ត្រូវអានឡើងវិញអោយសាម៉ីជនស្តាប់ ហើយបើសាមីជនថាត្រឹមត្រូវតាមចំណាំខ្លួនហើយ ត្រូវអោយចុះហត្ថលេខា ឬ ផ្តិតមេដៃស្តាំទទួលស្គាល់ ។

បើពិនិត្យទៅឃើញថាបណ្តឹងតវ៉ា បណ្តឹងបរិហារនោះត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នខ្លួនពិនិត្យដោះស្រាយគប្បីធ្វើសំណូមពរអោយម្ចាស់បណ្តឹងផ្តល់ថែមទៀតនូវភស្តុតាងចាំបាច់ផ្សេងៗ ដូចជាលិខិតឯកសារ ឬ សាក្សី ( បើមាន ) ហើយត្រូវគ្រប់គ្រងថែរក្សាភស្តុតាងទាំងនោះអោយបានត្រឹមត្រូវ និង គង់វង់។ យោងតាមពាក្យបណ្តឹង បើមានភាពសាមញ្ញអាចដោះស្រាយភ្លាមៗបានចាំបាច់ត្រូវកំណត់ពេលវេលាដោះស្រាយជាបន្ទាន់ ។ បើពាក្យបណ្តឹងមានភាពស្មុគស្មាញពុំអាចដោះស្រាយភ្លាមៗបានដោយរង់ចាំធ្វើអង្កេតសិននោះ ពេលវេលាដោះស្រាយគឺមិនត្រូវអោយលើសពីពេល ដែលច្បាប់បានកំណត់ទេ។

ក្នុងករណីដែលពាក្យបណ្តឹងមិនមែនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ប្រធានស្ថាប័ន ខ្លួនជាអ្នកពិនិត្យដោះស្រាយទេ ត្រូវផ្ញើរពាក្យបណ្តឹងនោះទៅអោយអង្គការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យ និង ដោះស្រាយ ហើយត្រូវជូនដំណឹងដល់ម្ចាស់បណ្តឹងអោយបានដឹងរឿងនេះ ប៉ុន្តែបើសាមីខ្លួនមកប្តឹងដោយផ្ទាល់មាត់នោះត្រូវណែនាំអ្នកប្តឹងអោយទៅជួបទាក់ទងជាមួយស្ថាប័នមានសមត្ថកិច្ចដោយផ្ទាល់តែម្តង ។

***II-ការគ្រប់គ្រងត្រួតពិនិត្យ និង សមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ***

ការគ្រប់គ្រងត្រួតពិនិត្យ និង សមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋត្រូវតែធ្វើអោយបានហ្មត់ចត់បំផុត ដើម្បីធានាការដោះស្រាយអោយបានត្រឹមត្រូវតាមច្បាប់កំណត់ ។

**១-ការគ្រប់គ្រងពាក្យបណ្តឹង**

ពាក្យបណ្តឹងតវ៉ា និង បណ្តឹងបរិហារ ដែលម្ចាស់បណ្តឹងកាន់មកផ្ទាល់ក្តី ផ្ញើមកក្តី ថ្នាក់លើប្រគល់អោយក្តី ទីកន្លែងផ្សេងទៀតបញ្ជូនមកក្តី កម្មាភិបាលដែលមានភារកិច្ចទទួលពាក្យបណ្តឹង ត្រូវចេះរបៀបរបបធ្វើការងារ គឺចុះលេខ ថ្ងៃ ខែ ឆ្នាំ ដែលបានទទួលក្នុងបញ្ជីប្រចាំថ្ងៃ ដោយសរសេរអោយបានច្បាស់អំពីកម្មវត្ថុបណ្តឹង ទំព័រនៃពាក្យបណ្តឹងនិងលិខិតផ្សេងៗទៀត ដែលជូនមកជាមួយ( បើសិនមាន ) ។ ក្នុងករណីដែលម្ចាស់បណ្តឹងកាន់ពាក្យមកប្តឹងផ្ទាល់ ចាំបាច់ត្រូវចេញបង្កាន់ដៃទទួលពាក្យ ទទួលលិខិតអោយទៅម្ចាស់បណ្តឹងវិញ ។

មុននឹងបញ្ជូនពាក្យបណ្តឹងអោយទៅអ្នកដែលមានភារកិច្ចដោះស្រាយ ត្រូវស្រាវជ្រាវ ពិនិត្យ បែងចែកប្រភេទពាក្យបណ្តឹងអោយបានច្បាស់ថា តើបណ្តឹងនោះជាបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ ហើយត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នណាជាអ្នកពិនិត្យ ដោះស្រាយ ថ្នាក់របស់ខ្លួន ថ្នាក់លើ ថ្នាក់ក្រោម ។

២-ត្រួតពិនិត្យសមត្ថកិច្ចដោះស្រាយបណ្តឹងនីមួយៗអោយបានត្រឹម ត្រូវតាមច្បាប់កំណត់ ។

ពាក្យបណ្តឹងណាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នខ្លួនដោះស្រាយគណៈកម្មាធិការត្រួតពិនិត្យទៅទីនោះត្រូវរាយការណ៍ជូនស្ថាប័នខ្លួន ដើម្បីមានវិធានការសម្រេចចាត់តាំងត្រួតពិនិត្យ ព្រមទាំងផ្តល់យោបល់មធ្យោបាយសម្ភារៈផ្សេងៗ បង្កលក្ខណៈងាយស្រួលក្នុងដំណើរការពិនិត្យដោះស្រាយ ។

ពាក្យបណ្តឹងណាដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ថ្នាក់ក្រោមដោះស្រាយត្រូវរាយការណ៍ជូនប្រធាន។ បើប្រធានឯកភាព ត្រូវបញ្ជូនពាក្យបណ្តឹងនោះអោយបានរួសរាន់ទាន់ពេលវេលា ទៅកន្លែងដែលមានសមត្ថកិច្ចដោះស្រាយហើយ ត្រូវមានវិធានការតាមដានអំពីលទ្ធផល និងថេរៈវេលា នៃការពិនិត្យដោះស្រាយ ។

ពាក្យបណ្តឹងណា ដែលមិនមែនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នខ្លួនពិនិត្យដោះស្រាយត្រូវបញ្ជូនពាក្យបណ្តឹងនោះជាបន្ទាន់ទៅអោយស្ថាប័នដែលមានសមត្ថកិច្ចពិនិត្យដោះស្រាយ ហើយត្រូវរាយការណ៍ ឬ ធ្វើលិខិតជូនដំណឹង ទៅម្ចាស់ពាក្យបណ្តឹងជ្រាបជាព័ត៌មាន ដើម្បីអោយទៅទាក់ទងផ្ទាល់នៅទីនោះ ។

ក្នុងករណីណាក៏ដោយ អ្នកទទួលពាក្យបណ្តឹងត្រូវរក្សាការសម្ងាត់លើខ្លឹមសារនៃពាក្យបណ្តឹង និងឈ្មោះអ្នកប្តឹងហើយមិនត្រូវបញ្ជូនពាក្យបណ្តឹង ឬ ចម្លងពាក្យបណ្តឹងជាលាយលក្ខអក្សរ ឬ ជាខ្សែអាត់ទៅឲ្យអង្គការ ឬ ដែលត្រូវគេប្តឹងនោះទេ ។ អ្នកទទួលពាក្យបណ្តឹងណា បញ្ជូនពាក្យបណ្តឹង ឬ ធ្វើឲ្យបែកការសម្ងាត់ លេចឮ ដល់អង្គការ ឬ បុគ្គលដែលត្រូវគេប្តឹង និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

***III-ការចាត់តាំងការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ***

១-មាត្រា ៨-៩-១៥ - និង ១៦ នៃច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ បានកំណត់ច្បាស់ពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ៖

-ការប្តឹងតវ៉ាចំពោះបុគ្គលដែលស្ថិតនៅក្របខ័ណ្ឌនៃអង្គការណាមួយត្រូវ ប្រធាន ឬ គណៈដឹកនាំនៃអង្គការនោះជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ ។ ឯការប្តឹងតវ៉ាចំពោះប្រធាន ឬ គណៈដឹកកាំនៃអង្គការណាមួយ ត្រូវប្រធាន ឬ គណៈដឹកនាំថ្នាក់លើដែលដឹកនាំអង្គការនោះផ្ទាល់ ជាអ្នកមានភារកិច្ចពិនិត្យ និងដោះស្រាយ ។

-ការប្តឹងបរិហារចំពោះបុគ្គលដែលស្ថិតនៅក្នុងក្របខ័ណ្ឌ នៃអង្គការមួយត្រូវប្រធានឬ គណៈដឹកនាំថ្នាក់លើនៃអង្គការនោះជាអ្នកមានភារកិច្ចពិនិត្យ និងដោះស្រាយ ។ ឯការប្តឹងបរិហារចំពោះប្រធាន ឬ គណៈដឹកនាំនៃអង្គការនេះត្រូវប្រធាន ឬ គណៈដឹកនាំថ្នាក់លើដែលដឹកនាំអង្គការនោះផ្តល់ ឬ ក៏ថ្នាក់ប្រធាន ឬ គណៈដឹកនាំថ្នាក់លើខ្ពស់ជាងអង្គការនោះមួយថ្នាក់ ជាអ្នកមានភារកិច្ចពិនិត្យ និង ដោះស្រាយ ។

ពាក្យបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារ បើពិនិត្យទៅឃើញថា មិនមែនជារឿងរដ្ឋបាល អង្គការរដ្ឋ អង្គការសង្គម ត្រូវបញ្ជូនទៅរដ្ឋអាជ្ញាអមតុលាការ បើរឿងនោះជារឿងព្រហ្មទណ្ឌ និង បញ្ជូនទៅតុលាការ បើរឿងនោះជារឿងគ្រួសារ ឬ រដ្ឋប្បវេណី ដើម្បីពិនិត្យ និង វិនិច្ឆ័យតាមច្បាប់ជាធរមាន ។ បើពិនិត្យទៅឃើញថា

បណ្តឹងតវ៉ា ឬ បណ្តឹងបរិហារមានការទាក់ទងនឹងលក្ខន្តិកៈរបស់អង្គការមហាជន ឬ សមាគមនានាត្រូវបញ្ជូនបណ្តឹងទៅអង្គការទាំងនោះ ដើម្បីពិនិត្យ និង ដោះស្រាយ ។ បើពិនិត្យឃើញថាបណ្តឹងតវ៉ា ឬ បណ្តឹងបរិហារគ្មានទាក់ទងនឹងបទបញ្ញត្តិណាមួយនៃលក្ខន្តិកៈរបស់អង្គការមហាជន ឬ សមាគមណាទេ ត្រូវបញ្ជូនបណ្តឹងអោយទាន់ពេលវេលាទៅអង្គការមានសមត្ថកិច្ច ដើម្បីពិនិត្យ និងដោះស្រាយ ។

២-គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ គ្រប់ផ្នែក ត្រូវជួយប្រធានខ្លួន ក្នុងការស៊ើបអង្កេត ស្រាវជ្រាវសំណុំរឿង រកភស្តុតាងជាលិខិត ឬ សាក្សីអោយបានគ្រប់គ្រាន់ ដើម្បីប្រធានមានមូលដ្ឋាន ធ្វើសេចក្តីសន្និដ្ឋានវាយតម្លៃអំពើខុសឆ្គងអោយបានត្រឹមត្រូវ និងយុត្តិធម៌ ។ ត្រូវយកចិត្តទុកដាក់អំពីថេរៈវេលានៃការដោះស្រាយដែលបានកំណត់ក្នុងច្បាប់ ។ ចំពោះរឿងណាដែលមានភាពស្មុគស្មាញពុំអាចដោះស្រាយបានទាន់ពេលវេលាកំណត់ត្រូវរាយការណ៍ជូនប្រធាន ដើម្បីសុំពន្យាពេលបើពុំដូច្នោះអ្នកដោះស្រាយត្រូវទទួលខុសត្រូវតាមច្បាប់ ។

៣-ក្នុងរយៈពេលដែលគណៈកម្មាធិការត្រួតពិនិត្យ កំពុងធ្វើអង្កេតស្រាវជ្រាវរកភស្តុតាង ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ប្រធានត្រូវតាមដាន និងណែនាំ ចំពោះបញ្ហាដែលចាំបាច់ ហើយផ្អែកតាមសេចក្តីសន្និដ្ឋាន និងមតិរបស់គណៈកម្មាធិការត្រួតពិនិត្យ ដើម្បីកំណត់ដោះស្រាយ ។ លើកលែងតែនៅមានបញ្ហាដែលមិនទាន់បានស្របច្បាប់ ឬ ពុំទាន់ច្បាស់លាស់ ប្រធានត្រូវស្រាវជ្រាវឡើងវិញ ឬ ជួបផ្ទាល់ជាមួយម្ចាស់បណ្តឹង ឬ ជួបផ្ទាល់ជាមួយអ្នកដែលមានការពាក់ព័ន្ធក្នុងបញ្ហានេះ ឬមួយក៏ប្រគល់ភារកិច្ចនេះទៅកម្មាភិបាលដែលទុកចិត្ត ដើម្បីស្រាវជ្រាវបន្ថែមអោយបានច្បាស់លាស់ មុនពេលកំណត់ការដោះស្រាយ ។

### *IV-ការត្រួតពិនិត្យ និង តាមដានការពិនិត្យដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ*

ដើម្បីអោយប្រជាជនយល់ច្បាស់ និង អនុវត្តបានត្រឹមត្រូវតាមច្បាប់ ស្តីពីការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ានិង បណ្តឹងបរិហាររបស់ពលរដ្ឋ ស្ថាប័នរដ្ឋផ្សព្វផ្សាយតាមការសែត វិទ្យុផ្សាយសំឡេង និងអង្គការមហាជន ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធផ្សព្វផ្សាយច្បាប់នេះអោយបានទូលំទូលាយ និងស៊ីជម្រៅទៅតាមគ្រប់ស្ថាប័នរដ្ឋ និង ក្នុងចំណោមប្រជាជនច្រើនកុះករ ។

១-គណៈកម្មាធិការត្រួតពិនិត្យគ្រប់ជាន់ថ្នាក់ មានភារកិច្ចត្រួតពិនិត្យដាស់តឿនក្រើនរំលឹកជាប្រចាំអំពីការអនុវត្តន៍ច្បាប់ ។

ក្នុងករណីដែលមានការប្រព្រឹត្តល្មើសច្បាប់ស្តីពីការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ត្រូវតែកំណត់អោយច្បាស់ចំពោះអ្នកប្រព្រឹត្តល្មើស ដើម្បីមានវិធានការដាក់ទណ្ឌកម្មតាមកំហុសធ្ងន់ ឬស្រាល ។

ក្រោយពេលពិនិត្យដោះស្រាយ ត្រូវធ្វើកំណត់ហេតុ សេចក្តីសន្និដ្ឋានបញ្ជាក់ វាយតម្លៃអំពីគុណសម្បត្តិ និងគុណវិបត្តិអោយបានច្បាស់លាស់ ។ ចំពោះគុណសម្បត្តិ ត្រូវមានវិធានការពង្រីកផ្សព្វផ្សាយជាសាធារណៈនូវបណ្តាបទពិសោធន៍ដ៏ល្អៗ រីឯគុណវិបត្តិត្រូវតែវិនិច្ឆ័យចំពោះអ្នកដែលបានប្រព្រឹត្តល្មើស ។

២- ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមរបបរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆមាសប្រចាំឆ្នាំ។

-របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ ត្រូវរៀបរាប់អោយបានច្បាស់លាស់ អំពីពាក្យបណ្តឹងដែលបានទទួលពាក្យបណ្តឹងដែលបានបញ្ជូនពាក្យបណ្តឹងដែលបានពិនិត្យដោះស្រាយផ្ទាល់ និងពាក្យបណ្តឹងមួយចំនួយទៀត ដែលកំពុងពិនិត្យ ។ ក្នុងចំណោមនោះត្រូវចេះបែងចែកប្រភេទពាក្យបណ្តឹង គឺបណ្តឹងតវ៉ាប៉ុន្មាន បណ្តឹងបរិហារប៉ុន្មាន ហើយមានពាក្យបណ្តឹងណាដោះស្រាយបានល្អទាន់ពេលវេលា និងបណ្តឹងណាមិនបានល្អ យឺតយូរហួសពេលកំណត់ក្នុងច្បាប់មូលហេតុអ្វី ? ។

-ឆ្លងតាមការពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ឬ បណ្តឹងបរិហាររបស់ពលរដ្ឋ បើមានរឿងណាមួយដោះស្រាយបានល្អត្រូវដកស្រង់ជាបទពិសោធន៍ ទុកជាគំរូរៀនសូត្រចំពោះគណៈកម្មាធិការត្រួតពិនិត្យទាំងឡាយ ។

របាយការណ៍ទាំងនោះ ត្រូវផ្ញើអោយបានទៀងទាត់ជូនថ្នាក់លើ និង ជូនគណៈកម្មាធិការត្រួតពិនិត្យដើម្បីតាមដាន និង បូកសរុប ។

ការងារពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា និង បណ្តឹងបរិហាររបស់ពលរដ្ឋ គឺជាការងារមួយដ៏សំខាន់ និង ជាចំបងក្នុងទំនាក់ទំនងរវាងបក្ស រដ្ឋ និង ប្រជាជន ហើយនេះក៏ជាភារកិច្ច និង កាតព្វកិច្ចរបស់ស្ថាប័នរដ្ឋទាំងអស់ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រី ជឿជាក់ថាស្ថាប័នគ្រប់ថ្នាក់នឹងយល់ជ្រួតជ្រាបនូវខ្លឹមសារ សរសេរចរណែនាំខាងលើនេះហើយអនុវត្តបានហ្មត់ចត់ និងត្រឹមត្រូវបំផុតដើម្បីធានាអោយច្បាប់ស្តីពីការពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹង បរិហាររបស់ពលរដ្ឋ ត្រូវបានគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ។

ភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៨៤

ជ,ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធានស្តីទី

ហត្ថលេខា និង ត្រា

**ចាន់ សុទ្ធ**